00916795 E138/1/10/1/5/8/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 31-May-2013, 15:41
CMS/CFO: Uch Arun

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (១៦)

Case File/Dossier Nº. 002/19-09-2007-ECCC-TC/SC (16)

| | |
|---|---|
| **នៅចំពោះមុខ៖** | **ចៅក្រម គង់ ស្រីម ប្រធាន** |
| | **ចៅក្រម Chandra Nihal JAYASINGHE** |
| | **ចៅក្រម Agniezska KLONOWIECKAMILART** |
| | **ចៅក្រម ម៉ុង មុន្នីចរិយា** |
| | **ចៅក្រម Florence Ndepele Mwachande MUMBA** |
| | **ចៅក្រម សោម សិរីវឌ្ឍ** |
| | **ចៅក្រម យ៉ា ណារិន** |
| **កាលបរិច្ឆេទឯកសារ៖** | **ថ្ងៃទី ៣១ /ខែ ឧសភា /ឆ្នាំ ២០១៣** |
| **ភាសាដើម៖** | **ខ្មែរ/អង់គ្លេស** |
| **ចំណាត់ថ្នាក់ឯកសារ៖** | **សាធារណៈ** |

---

# សេចក្តីសម្រេចលើសំណើរបស់អង្គជំនុំជម្រះសាលាដំបូង និងមេធាវីការពារក្តី អៀង ធីរិទ្ធ សុំការណែនាំ និងការបញ្ជាក់បំភ្លឺ

---

| | |
|---|---|
| **សហព្រះរាជអាជ្ញា** | **ជនជាប់ចោទ** |
| ជា លាង | អៀង ធីរិទ្ធ |
| Andrew CAYLEY | |

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

ផាត់ ពៅស៊ាង

Diana ELLIS

**អាណាព្យាបាលជនជាប់ចោទ**

អៀង វិជីដា

1. **អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់ទោសឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងពេលពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង "អ.វ.ត.ក")បានទទួល សំណើរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ("មេធាវីការពារក្តី")ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង កាលពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៣ ស្នើសុំអង្គជំនុំជម្រះសាលាដំបូងធ្វើការបញ្ជាក់ បំភ្លឺពីការអនុវត្តនីតិវិធីនៃការត្រួតពិនិត្យតាមផ្លូវតុលាការរបស់អង្គជំនុំជម្រះតុលាការកំពូល ចំពោះ អៀង ធីរិទ្ធ កាលពីថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ ("សំណើ" និង "សេចក្តីសម្រេចស្តីពីការត្រួតពិនិត្យ តាមផ្លូវតុលាការ")[1]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជូនសំណើមកអង្គជំនុំជម្រះតុលាការកំពូល កាលពីថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៣ ("សេចក្តីសម្រេចស្តីពីការអនុវត្ត")[2]។

2. នៅក្នុងសេចក្តីសម្រេចស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឱ្យ អៀង ធីរិទ្ធ គោរពទៅតាមវិធានការមួយចំនួននៃការត្រួតពិនិត្យតាមផ្លូវតុលាការមានដូចខាងក្រោម៖

    1) ជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង ឬមន្ត្រីដែលត្រូវបានជ្រើសតាំងដោយអង្គជំនុំជម្រះសាលាដំបូង មុនពេលផ្លាស់ប្តូរអាសយដ្ឋានស្នាក់នៅបច្ចុប្បន្នរបស់ជនជាប់ចោទ
    2) មិនឱ្យចាកចេញពីព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង,
    3) ទទួលការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្ររៀងរាល់ប្រាំមួយខែម្តង ដោយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ដែលត្រូវបានចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង,

---

[1] សំណើរបស់មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ សុំការបញ្ជាក់បំភ្លឺពីការអនុវត្ត "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ" របស់អង្គជំនុំជម្រះតុលាការកំពូល E138/1/10/1/5/8 ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៣។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ E138/1/10/1/5/7 ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២។

[2] សេចក្តីសម្រេចស្តីពីការអនុវត្ត"សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធដោយឥតលក្ខខណ្ឌ"របស់អង្គជំនុំជម្រះតុលាការកំពូល (E138/1/10/1/5/8) E138/1/10/1/5/8/1, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៣។

4) ត្រូវបង្ហាញខ្លួនសម្រាប់ការត្រួតពិនិត្យផ្នែកសន្តិសុខ ដែលអនុវត្តដោយនគរបាលយុត្តិធម៌មួយខែម្តង ដើម្បីបញ្ជាក់ការអនុវត្តវិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការដែលបានលើកឡើងខាងលើ។ ជម្រើសផ្សេងមួយទៀត អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចថា ជនជាប់ចោទត្រូវផ្តល់របាយការណ៍ប្រចាំខែ តាមរយៈអាណាព្យាបាលទូទៅរបស់ជនជាប់ចោទ ជូនដល់អង្គជំនុំជម្រះសាលាដំបូង ឬមន្ត្រីដែលបានជ្រើសតាំងដោយអង្គជំនុំជម្រះសាលាដំបូង ដើម្បីបញ្ជាក់ពីការអនុវត្តតាមវិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការដែលបានរៀបរាប់ខាងលើ។[3]

3. អង្គជំនុំជម្រះតុលាការកំពូលក៏បានបង្គាប់ផងដែរឲ្យប្រគល់លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណរបស់ជនជាប់ចោទទៅអាណាព្យាបាលទូទៅ ដោយកំណត់លក្ខខណ្ឌថា មិនត្រូវប្រើលិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណទាំងនេះ ក្នុងគោលបំណងធ្វើដំណើរទៅបរទេស ដោយគ្មានការអនុញ្ញាតជាមុនពីអង្គជំនុំជម្រះសាលាដំបូងនោះទេ[4]។

4. បន្ថែមពីលើនេះ អង្គជំនុំជម្រះតុលាការកំពូលបង្គាប់ដល់នគរបាលយុត្តិធម៌ ឲ្យធ្វើការត្រួតពិនិត្យជាប្រចាំខែនៅអាសយដ្ឋានដែលជនជាប់ចោទផ្តល់ជូនទៅតុលាការ ដើម្បី ១) បញ្ជាក់ថា ជនជាប់ចោទនៅតែស្នាក់នៅអាសយដ្ឋាននេះ និងមិនបានចាកចេញពីប្រទេស ២) រាយការណ៍អំពីការគម្រាមកំហែងណាមួយចំពោះសុវត្ថិភាពរបស់ជនជាប់ចោទ អនុលោមតាមកាតព្វកិច្ចរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការធានាសន្តិសុខរបស់ជនជាប់ចោទ និងរាយការណ៍ទៅកាន់អង្គជំនុំជម្រះសាលាដំបូង[5]។

5. អង្គជំនុំជម្រះតុលាការកំពូលក៏បានណែនាំបន្ថែមដល់ការិយាល័យរដ្ឋបាល អ.វ.ត.ក ឲ្យផ្តល់ការគាំទ្រចាំបាច់ផ្នែករដ្ឋបាលទាំងអស់ ក្នុងការអនុវត្តសេចក្តីសម្រេចស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការនេះ ដោយរួមទាំងការជូនដំណឹងអំពីសេចក្តីសម្រេចនេះ ដល់អាជ្ញាធរពាក់ព័ន្ធរបស់កម្ពុជាក្នុងការចាត់វិធានការផ្សេងៗ[6]។

---

[3] សេចក្តីសម្រេចស្តីពីការត្រួតពិនិត្យ ទំព័រ ៤៥-៤៦។

[4] សេចក្តីសម្រេចស្តីពីការត្រួតពិនិត្យ ទំព័រ ៤៦។

[5] សេចក្តីសម្រេចស្តីពីការត្រួតពិនិត្យ ទំព័ ៤៦។

[6] សេចក្តីសម្រេចស្តីពីការត្រួតពិនិត្យ ទំព័រ ៤៦។

6. ក្រោយមកទៀត មេធាវីការពារក្តីបានស្នើសុំដល់"អង្គជំនុំជម្រះសាលាដំបូងឱ្យផ្តល់សេចក្តីបញ្ជាក់ដល់ជនជាប់ចោទ អំពីបញ្ហាថាតើ លក្ខខណ្ឌត្រួតពិនិត្យតាមផ្លូវតុលាការដែលដាក់មកលើជនជាប់ចោទ ដែលបង្គាប់ដោយសេចក្តីសម្រេចអង្គជំនុំជម្រះតុលាការកំពូលនេះ នឹងត្រូវយកមកអនុវត្តតាមរបៀបយ៉ាងដូចម្តេចខ្លះ"[7]។ ជាពិសេសមេធាវីការពារក្តីស្នើសុំព័ត៌មានលម្អិតស្តីពីរបៀបនៃការជូនដំណឹង[8] ការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ[9] និងការត្រួតពិនិត្យផ្នែកសន្តិសុខ[10]។

7. នៅក្នុងសេចក្តីសម្រេចស្តីពីការអនុវត្ត អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលសំណើ ដោយយល់ឃើញថា ខ្លួនមិនមានយុត្តាធិការ"បង្ហាញមតិយោបល់ ឬបញ្ជាក់បំភ្លឺ"លើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលឡើយ[11]។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានបញ្ជូនសំណើមកអង្គជំនុំជម្រះតុលាការកំពូល"ដើម្បីផ្តល់ការណែនាំ និងសេចក្តីចង្អុលបង្ហាញបន្ថែម"[12]។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់អង្គជំនុំជម្រះតុលាការកំពូលអំពីវិធានការនានា ដែលខ្លួនមានបំណងប្រើប្រាស់ដើម្បីអនុវត្តសេចក្តីសម្រេចស្តីពីការត្រួតពិនិត្យដោយ"អាស្រ័យលើការណែនាំបន្ថែម" ពីអង្គជំនុំជម្រះតុលាការកំពូល[13]។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងក៏បានដាក់សំណើផ្ទាល់ខ្លួនសុំការបញ្ជាក់បំភ្លឺពីអង្គជំនុំជម្រះតុលាការកំពូល ទៅលើបញ្ហាមួយចំនួនតូចដូចជា ថាតើ ការពិនិត្យជាប្រចាំផ្នែកវេជ្ជសាស្ត្រ ត្រូវកម្រិតត្រឹមស្ថានភាពសតិបញ្ញាស្មារតីនៃជនជាប់ចោទតែប៉ុណ្ណោះ ឬមួយយ៉ាងណា ហើយប្រសិនបើមិនកម្រិតត្រឹមស្ថានភាពសតិបញ្ញាស្មារតីទេ តើនរណាជាអ្នកទទួលខុសត្រូវលើការចំណាយទៅលើការវាយតម្លៃទាំងនេះ ព្រមទាំង ថាតើ ទណ្ឌកម្មសមស្របណាខ្លះ ដែលអាចធ្វើឡើង នៅពេលដែលមានការរំលោភបំពានទៅលើលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការលើ អៀង ធីរិទ្ធ ហើយ តើនរណាជាអ្នកទទួលទណ្ឌកម្មនេះ[14]។

---

[7] សំណើ កថាខណ្ឌ ១ សូមមើលផងដែរ សំណើ កថាខណ្ឌ ៧ និង ២៩។

[8] សំណើ កថាខណ្ឌ៨, ២៤ -២៥។

[9] សំណើ កថាខណ្ឌ៩ -១៤។

[10] សំណើ កថាខណ្ឌ ១៥ -២៣។

[11] សេចក្តីសម្រេចស្តីពីការអនុវត្ត កថាខណ្ឌ ៦ ទំព័រ ៤។

[12] សេចក្តីសម្រេចស្តីពីការអនុវត្ត កថាខណ្ឌ ៧ ទំព័រ ៤។

[13] សេចក្តីសម្រេចស្តីពីការអនុវត្ត កថាខណ្ឌ ៧ - ៨ ទំព័រ ៥។

[14] សេចក្តីសម្រេចស្តីពីការអនុវត្ត កថាខណ្ឌ ៩ ទំព័រ ៥។

8. ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ពុំមានមូលដ្ឋានច្បាប់ណាមួយសម្រាប់ឱ្យអង្គជំនុំជម្រះសាលាដំបូង "បញ្ជូន" សំណើនេះមកអង្គជំនុំជម្រះតុលាការកំពូលនោះទេ។ ក្នុងការដែលមិនអនុវត្តយុត្តាធិការរបស់ខ្លួនដោយមិនធ្វើការសម្រេចលើសំណើនេះ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើមាត្រា ៦០៦(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា[15] ដែលចែងថា "គ្រប់ការលំបាកក្នុងការបកស្រាយសេចក្តីសម្រេចរបស់តុលាការ ត្រូវដាក់ជូនតុលាការដែលបានប្រកាសសេចក្តីសម្រេចនោះពិនិត្យ"។ ក្នុងករណីនេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងធ្វើការកំណត់ខុសចំពោះសំណើ ថាជាសំណើសុំការបញ្ជាក់បំភ្លឺលើភាពមិនច្បាស់លាស់ក្នុងការបកស្រាយសេចក្តីសម្រេចស្តីពីការត្រួតពិនិត្យទៅវិញ។ តាមពិតទៅ ច្បាស់ណាស់ថា សំណើនេះ គឺជាសំណើសុំការបញ្ជាក់ច្បាស់លាស់លើផ្នែកភស្តុភារ ពាក់ព័ន្ធទៅនឹងការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះសេចក្តីសម្រេចស្តីពីការត្រួតពិនិត្យ។ វិធីសាស្ត្រដែលអង្គជំនុំជម្រះសាលាដំបូងគ្រោងនឹងអនុវត្តទៅតាមការបង្គាប់ ដូចមានចែងក្នុងសេចក្តីសម្រេចស្តីពីការត្រួតពិនិត្យ បើតាមនិយមន័យ គឺអាចធ្វើឡើងបានដោយអង្គជំនុំជម្រះសាលាដំបូងតែម្នាក់គត់។ ចំណុចនេះត្រូវបានបង្ហាញនៅក្នុងសេចក្តីសម្រេចស្តីពីការអនុវត្ត*ទៅតាមគំនិតផ្តួចផ្តើមរបស់ខ្លួន* ដោយក្នុងសេចក្តីសម្រេចនោះ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់អង្គជំនុំជម្រះតុលាការកំពូលអំពីវិធានការនានាដែលខ្លួនបាន"ប្រមើលមើល"[16] ថានឹងប្រើប្រាស់ ដើម្បីអនុវត្តសេចក្តីសម្រេចស្តីពីការត្រួតពិនិត្យ។ តាមរយៈនេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចទទួលយកសំណើ ហើយបានផ្តល់ព័ត៌មានដែលមេធាវីការពារក្តីបានស្នើសុំផងដែរ។

9. ការពិនិត្យឡើងវិញទៅលើវិធានការដែលអង្គជំនុំជម្រះសាលាដំបូងបានស្នើឡើង បង្ហាញឱ្យឃើញថា អង្គជំនុំជម្រះសាលាដំបូងបានត្រៀមខ្លួនជាស្រេចក្នុងការដោះស្រាយការព្រួយបារម្ភរបស់មេធាវីការពារក្តីរួចហើយ ហើយវិធានការដែលបានលើកឡើងនោះ មិនបានបង្ហាញពីភាពមិនសមហេតុផល *ដែលជាសេចក្តីបញ្ជាក់ដំបូង*ណាមួយឡើយ។ ជាពិសេស អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ព័ត៌មានលម្អិតអំពីរបៀបនៃការជូនដំណឹង[17] ការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ[18] និងការត្រួតពិនិត្យផ្នែកសន្តិសុខ

[15] សេចក្តីសម្រេចស្តីពីការអនុវត្ត កថាខណ្ឌ ៦ ជើងទំព័រ ៣។

[16] សេចក្តីសម្រេចស្តីពីការអនុវត្ត កថាខណ្ឌ ៨។

[17] សេចក្តីសម្រេចស្តីពីការអនុវត្ត កថាខណ្ឌ ៨ (ផ្នែក ៣.១.១.(ក))។

[18] សេចក្តីសម្រេចស្តីពីការអនុវត្ត កថាខណ្ឌ ៨ (ផ្នែក ៣.១.១.(ក) - (ខ) ។

ដែលត្រូវអនុវត្ត[19]។ ហេតុដូច្នេះ សេចក្តីសម្រេចស្តីពីការត្រួតពិនិត្យ គឺពិតជាច្បាស់លាស់គ្រប់គ្រាន់សម្រាប់ចាត់វិធានការសមស្រប ហើយពុំមានមូលដ្ឋាន ឬភាពចាំបាច់ណាមួយ សម្រាប់ឱ្យអង្គជំនុំជម្រះតុលាការកំពូល ផ្តល់ការណែនាំបន្ថែមទៀតឡើយ។

10. ទាក់ទងនឹងសំណើផ្ទាល់ខ្លួនរបស់អង្គជំនុំជម្រះសាលាដំបូងសុំការបញ្ជាក់បំភ្លឺនោះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បញ្ហាដែលបានចោទសួរនេះ ប្រហាក់ប្រហែលគ្នាដែរ ពុំបានបង្ហាញពីភាពមិនច្បាស់លាស់នៅក្នុងសេចក្តីសម្រេចស្តីពីការត្រួតពិនិត្យនោះទេ ដូចដែលបានបង្ហាញតាមរយៈលទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការបង្កើតវិធានការសមស្របក្នុងការអនុវត្ត និងការធ្វើសេចក្តីសន្និដ្ឋានយ៉ាងសមស្រប។ ទោះបីជាសេចក្តីសម្រេចស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការបានផ្តល់ជាក្របខណ្ឌចាំបាច់នានាសម្រាប់អនុវត្តវិធានការដែលបានដាក់ចេញក៏ដោយ ក៏ការអនុវត្តវិធានការទាំងនោះត្រូវបានធ្វើប្រតិភូកម្មទៅឱ្យអង្គជំនុំជម្រះសាលាដំបូង ដែលជាអ្នកត្រួតពិនិត្យទៅលើ អៀង ធីរិទ្ធ ហើយក៏ជាស្ថាប័នដែលល្អបំផុតសម្រាប់ធ្វើការរៀបចំផ្នែកភស្តុភារសមស្រប និងជាស្ថាប័នដែលជាប់កាតព្វកិច្ចក្នុងការអនុវត្តសេចក្តីសម្រេចស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយពេញលេញ សុចរិត និងទាន់ពេលវេលា។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងចាំបាច់ត្រូវចេញដីកាសម្រេចស្តីពីការអនុវត្ត ដោយពិគ្រោះជាមួយភាគី និងធ្វើការសម្របសម្រួលជាមួយការិយាល័យរដ្ឋបាល ដើម្បីទទួលការជួយគាំទ្រផ្នែករដ្ឋបាលដែលចាំបាច់នានា។

11. ទោះជាយ៉ាងណាក៏ដោយ ដើម្បីជៀសវាងការពន្យារពេលបន្ថែមទៀតនោះ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា ការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្ររៀងរាល់ឆមាសនោះ គឺក្នុងគោលបំណងត្រួតពិនិត្យជាទៀតទាត់ទៅលើបញ្ហា ដែលនាំឱ្យមានការសម្រេចថា អៀង ធីរិទ្ធ ពុំមានសម្បទាគ្រប់គ្រាន់សម្រាប់ការចូលរួមក្នុងសវនាការ ដែលសំដៅលើស្ថានភាពសតិបញ្ញាចុះខ្សោយរបស់ជនជាប់ចោទ[20]។ សេចក្តីសម្រេចស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការបញ្ជាក់យ៉ាងច្បាស់ទៅលើចំណុចនេះ គឺថា ការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ ដែលមានគោលដៅបញ្ជាក់ ថាតើ ស្ថានភាពសតិបញ្ញារបស់ អៀង ធីរិទ្ធ មានភាពប្រសើរឡើង ឬថយចុះ ព្រមទាំងធ្វើការវាយតម្លៃពីតម្រូវការក្នុងការព្យាបាល[21]។ មិនមានមូលដ្ឋានសម

[19] សេចក្តីសម្រេចស្តីពីការអនុវត្ត កថាខណ្ឌ ៨ (ផ្នែក ៣.១.៣.(ក)) ។

[20] សេចក្តីសម្រេចស្តីពីការអនុវត្ត កថាខណ្ឌ ៩ (ផ្នែក ៣.២.១.(ក))។

[21] *សូមមើល*ជាពិសេស សេចក្តីសម្រេចស្តីពីការត្រួតពិនិត្យ កថាខណ្ឌ ៦៧ ("នៅដំណាក់កាលនេះ ជាដំណាក់កាលដែលជនជាប់ចោទទើបត្រូវបានដោះលែងពីមន្ទីរឃុំឃាំង អ.វ.ត.ក ការវាយតម្លៃវេជ្ជសាស្ត្រគឺជាវិធានការដើម្បីពិនិត្យផ្ទៀងផ្ទាត់ថា ស្ថានភាព

ស្របណាមួយសម្រាប់ទាញសន្និដ្ឋានថា ការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រត្រូវធ្វើឡើងហួសពីគោលដៅនេះឡើយ[22]។

12. ចំពោះសំណើរបស់អង្គជំនុំជម្រះសាលាដំបូងសុំឱ្យមានការបញ្ជាក់បំភ្លឺ ពាក់ព័ន្ធនឹង"ទណ្ឌកម្មសមស្រប"នោះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា នេះគឺជាសំណួរជាលក្ខណៈសម្មតិកម្ម ដែលមិនទាក់ទងនឹងភាពមិនច្បាស់លាស់ណាមួយ នៅក្នុងសេចក្តីសម្រេចស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការនោះទេ។ ហេតុដូច្នេះ មិនមានមូលដ្ឋានច្បាស់លាស់ណាមួយសម្រាប់ឱ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើការដោះស្រាយលើបញ្ហានេះទេ។ ទោះបីជាយ៉ាងដូច្នេះក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ដំណើរការប្រហាក់ប្រហែលគ្នាសម្រាប់ការបំភ្លឺ ឬការកំណត់ជាក់លាក់ស្តីពីបញ្ហាផ្លូវច្បាប់ គឺមានលក្ខណៈទូទៅជារួមនៅក្នុងកម្រិតអន្តរជាតិ[23]។ ផ្អែកតាមមូលដ្ឋាននេះ អង្គជំនុំ

ជំងឺរបស់ជនជាប់ចោទគឺជាស្ថានភាពពិតប្រាកដឬទេ ដើម្បីពិនិត្យការប្រែប្រួល កាលៈទេសៈ និងដើម្បីផ្តល់លទ្ធភាពក្នុងការចាប់ផ្តើមវិធីព្យាបាលថ្មីៗ ប្រសិនបើមាន")។

[22] អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា ការយល់ច្រលំកើតចេញពីពាក្យពេចន៍នៅក្នុងកថាខណ្ឌ ៦៨ នៃសេចក្តីសម្រេចស្តីពីការត្រួតពិនិត្យដែលពាក់ព័ន្ធនឹង"ស្ថានភាពចុះខ្សោយទូទៅ"របស់ អៀង ធីរិទ្ធ។ *សូមមើល* សេចក្តីសម្រេចស្តីពីការអនុវត្តកថាខណ្ឌ ៩ (ផ្នែក ៣.២.១.(ក))។ បើពិនិត្យមើលទៅលើកថាខណ្ឌ ៦៨ ទាំងមូល អត្ថន័យមានភាពច្បាស់លាស់ណាស់ថា ការលើកយោងរបស់អង្គជំនុំជម្រះតុលាការកំពូល ទៅលើស្ថានភាពសុខភាពទូទៅរបស់ អៀង ធីរិទ្ធ គឺជាផ្នែកមួយនៃការអនុវត្តឱ្យមានតុល្យភាពរវាងសិទ្ធិជាឯកជន ធៀបនឹងផលប្រយោជន៍ នៅពេលដែលធ្វើការត្រួតពិនិត្យសុខភាពជាទៀងទាត់លើស្ថានភាពសតិបញ្ញារបស់គាត់។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលធ្វើការយោងបែបនេះ ដើម្បីពន្យល់ថា ការត្រួតពិនិត្យសុខភាពប្រចាំឆមាស ដែលបង្គាប់ដោយតុលាការ ទៅលើស្ថានភាពសតិបញ្ញារបស់ អៀង ធីរិទ្ធ គឺមានផលរំខានតិចតួចបំផុត ដោយសារតែ អៀង ធីរិទ្ធ ក៏ចាំបាច់ត្រូវការជំនួយផ្នែកវេជ្ជសាស្ត្រទាក់ទងទៅនឹងសុខភាពទូទៅរបស់គាត់ផងដែរ។

[23] *សូមមើល* វិធាន ៦៨(ឆ) និងវិធាន ១៧៦*ស្ទួន*(ក) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់, វិធាន ៧២ នៃវិធានស្តីពីនីតិវិធី និងភស្តុតាង របស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន, *រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo*, ការបញ្ជាក់បំភ្លឺ, ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៧, រឿងក្តី No. ICC-01/04-01/06-904 (OA 8) និងនៅក្នុងរឿងក្តីដដែល ការបញ្ជាក់បំភ្លឺរបស់ អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៦, រឿងក្តី ICC-01/04-01/06-590 (OA 4), *រដ្ឋអាជ្ញា តទល់នឹង Kordić and Čerkez*, រឿងក្តី No. IT-95-14/2, សេចក្តីសម្រេចលើ សារណាមេធាវីការពារក្តី សុំការបញ្ជាក់បំភ្លឺ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៩, *រដ្ឋអាជ្ញា តទល់នឹង Slobodan Milošević*, រឿងក្តី No. IT-02-54, សេចក្តីសម្រេចលើសារណារបស់រដ្ឋអាជ្ញា សុំការបញ្ជាក់បំភ្លឺ ឬការទូទាត់សងផ្សេង ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០២, *រដ្ឋអាជ្ញា តទល់នឹង Haradinaj និងអ្នកដទៃ* រឿងក្តី No. IT-04-84 សេចក្តីសម្រេចលើសារណាសុំការបញ្ជាក់បំភ្លឺ ចំពោះសេចក្តីណែនាំអនុវត្ត ស្តីពីនីតិវិធីក្នុងការដាក់សារណាជាលាយលក្ខណ៍អក្សរ ក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ និងការពន្យាពេល, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៥។ ការអនុវត្តក្នុងប្រព័ន្ធអង់គ្លូសាក់សុង ក៏បានចែងផងដែរពីការប្តឹងសាទុក្ខ "តាមបែបរឿងក្តី

ជម្រះតុលាការកំពូលពិចារណាឃើញថា នៅពេលមានតម្រូវការសម្រាប់ផលប្រយោជន៍យុត្តិធម៌ អង្គជំនុំជម្រះអាចនឹងទទួលយកសំណើសម្រាប់ការណែនាំខាងផ្លូវច្បាប់។

13. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា បញ្ហាដែលបានលើកឡើងដោយអង្គជំនុំជម្រះសាលាដំបូង មានចែងនៅក្នុងច្បាប់ជាតិ ដែលគេអាចសន្មតបានថា អង្គជំនុំជម្រះសាលាដំបូងដឹងពីបញ្ហានេះ។ យោងតាមវិធានស្តីពីការបកស្រាយលក្ខន្តិកៈ បញ្ញត្តិច្បាប់ គប្បីត្រូវបានបកស្រាយក្នុងន័យមួយដែលមានអនុភាព[24]។ វាមានសារៈប្រយោជន៍ពេលពិចារណាឃើញថា វិធានការនៃការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺវិធានការដែលមានលក្ខណៈពុំសូវរឹតត្បិត ដូចការឃុំខ្លួនឡើយ។ ហេតុនេះ យោងតាមរដ្ឋធម្មនុញ្ញកម្ពុជា វិធានការនេះ គប្បីត្រូវបានពិចារណាដោយតុលាការ*ខ្លួនឯងផ្ទាល់* ទាក់ទងទៅនឹងជនជាប់ឃុំណាមួយ នៅពេលដែលកាលៈទេសៈអនុញ្ញាត[25]។ ហេតុនេះ ដើម្បីជាប្រយោជន៍ទូទៅ និងក្នុងការជៀសវាងការពន្យារពេល ឬការបដិសេធមិនសមស្របណាមួយនាពេលអនាគត ចំពោះការអនុវត្តវិធានការស្តីពីការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលើជនជាប់ចោទ អង្គជំនុំជម្រះតុលាការកំពូលនឹងជួយដោះស្រាយលើសំណើសុំការណែនាំរបស់អង្គជំនុំជម្រះ

---

ដែលបានបញ្ជាក់” ដែលជាសេចក្តីប្រកាសអង្គហេតុ ដែលរៀបចំដោយតុលាការមួយ សម្រាប់តុលាការដទៃបញ្ចេញមតិយោបល់។ ដំណើរការប្តឹងសាទុក្ខ ធ្វើឡើងដោយអនុលោមតាមសំណើដែលលើកឡើងដោយតុលាការជាន់ទាប តាមការទាមទាររបស់ភាគី។ ដំណើរការនេះត្រូវបានប្រើប្រាស់ជាច្រើនលើកនៅចំពោះមុខតុលាការអង់គ្លេស និង វែលស៍ (Welse)។ សូមមើលជាឧទាហរណ៍ *អង្គជំនុំជម្រះ តទល់នឹង DPP* [2012] EWHC 2157; *រឿងក្តី DPP ទល់នឹង Bayer* [2004] 1 Cr. App. Rep. 493។ ដំណើរការប្រហាក់ប្រហែលគ្នានេះក៏ត្រូវបានធ្វើឡើងនៅក្នុងសាធារណរដ្ឋអៀរឡង់ផងដែរ (សូមមើលតុលាការ (បទប្បញ្ញត្តិបន្ថែម) បញ្ញត្តិ ១៩៦១, s. 52), ប្រទេសនូវែលហ្សេឡង់ (កិច្ចដំណើរការនីតិវិធីសង្ខេប បញ្ញត្តិ ១៩៥៧, s.104, *រឿងក្តី Radhi ទល់នឹង Police* [2013] NZHC 163), ប្រទេសអូស្ត្រាលី (សូមមើលតុលាការសហព័ន្ធ អូស្ត្រាលី បញ្ញត្តិ ១៩៧៦ s. 26)។ បន្ថែមពីលើនេះ តុលាការជាតិ នៅក្នុងសហភាពអឺរ៉ុប អាចធ្វើសំណើសុំការបញ្ជាក់បំភ្លឺទៅលើចំណុចនានា នៃច្បាប់សហភាពអឺរ៉ុប ពីតុលាការយុត្តិធម៌អឺរ៉ុបបាន។ សូមមើលមាត្រា ២៦៧ នៃសន្ធិសញ្ញាស្តីពីការប្រព្រឹត្តិទៅនៃសហភាពអឺរ៉ុប។

[24] *សូមមើល ឧ. រឿងក្តី Lampkins ទល់នឹង Commonwealth*, 4 Va. សំណើសុំលេខ 709, 607 S.E.2d 722 (2005): “គឺជាវិធានមួយស្តីពីការបកស្រាយដែលថា លក្ខន្តិកៈគប្បីបកស្រាយក្នុងន័យថា មានអានុភាព និងពុំត្រូវបានរកឃើញថាគ្មានន័យ និងមិនច្បាស់លាស់ឡើយ”, ដកស្រង់ចេញពី *រឿងក្តី McFadden ទល់នឹង McNorton*, 193 Va. 455, 461, 69 S.E.2d 445, 449 (1952)។

[25] ទោះបីយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងទំនងជាបន្តអនុវត្តការត្រួតពិនិត្យតាមផ្លូវតុលាការក្នុងរឿងក្តីបច្ចុប្បន្ន។ *សូមមើល* សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងដីការបស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ឯកសារលេខ E138/1/7, ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១, កថាខណ្ឌ ៤៤ ដល់ ៤៨។

សាលាដំបូង។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលសង្កត់ធ្ងន់ថា អង្គជំនុំជម្រះអាចឆ្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះសាលាដំបូង ត្រឹមតែជាលក្ខណៈអរូបីយនៃច្បាប់ជាធរមានតែប៉ុណ្ណោះ។

14. អង្គជំនុំជម្រះតុលាការកំពូលសូមរំឮកថា "ការលំបាកក្នុងការអនុវត្តទណ្ឌកម្មលើជនជាប់ចោទ ប្រសិនបើជនជាប់ចោទមិនគោរពតាមកាតព្វកិច្ចដែលបានដាក់ដោយតុលាការ ពុំបានធ្វើឱ្យកាតព្វកិច្ចទាំងនេះលែងមានសុពលភាពនោះទេ"[26]។ ការរំលោភបំពានទៅលើលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការអាចនាំឱ្យមានផលវិបាកជាច្រើន តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង និងច្បាប់កម្ពុជាស្តីពីនីតិវិធីព្រហ្មទណ្ឌ[27]។ បើក្នុងន័យជាក់ស្តែង ការទទួលខុសត្រូវចំពោះការរំលោភបំពានបែបនេះ មិនមែនអាស្រ័យទៅលើការសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ឬការមានសមត្ថភាពសម្រាប់ធ្វើបណ្តឹងរដ្ឋប្បវេណីនោះទេ ប៉ុន្តែការទទួលខុសត្រូវបែបនេះស្ថិតលើសមត្ថភាពជាក់ស្តែងក្នុងការយល់ដឹង និងគ្រប់គ្រងសកម្មភាពរបស់ខ្លួន នៅពេលដែលមានអំពើសកម្ម ឬអកម្ម ដែលរងការជំទាស់នោះ[28]។ ការរកឃើញពីភាពគ្មានសម្បទាគ្រប់គ្រាន់ ពុំបណ្តាលឱ្យដោះបន្ទុកជនជាប់ចោទចេញពីដំណើរការនីតិវិធីនាពេលអនាគតណាមួយឡើយ[29]។ បញ្ហានៃការមានសម្បទា និងការតំណាងនៅក្នុងរឿងក្តីនាពេល

---

[26] សេចក្តីសម្រេចស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការ កថាខណ្ឌ ៦២។

[27] *សូមមើលឧ.*មាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា("ប្រសិនបើជនត្រូវចោទគេចវេះដោយចេតនាពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឱ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នបាន ទោះបីជាទោសជាប់ពន្ធនាគារដែលត្រូវរងនោះមានថិរវេលាប៉ុន្មានក៏ដោយ ហើយទោះបីជាជនត្រូវចោទត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលអតិបរមា [...] ការឃុំខ្លួនបណ្តោះអាសន្នដែលសម្រេចតាមមាត្រានេះ មិនអាចឱ្យលើសពី ៤(បួន) ខែ ចំពោះនីតិជន និង ២(ពីរ) ខែ ចំពោះអនីតិជន។

[28] *សូមមើល*មាត្រា ៣១ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។ ប៉ុន្តែតុលាការត្រូវគិតគូរអំពីបញ្ហានេះ កាលណាតុលាការកំណត់ទោស។ កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ")។

[29] គោលការណ៍នេះត្រូវដាក់បញ្ចូលជាមួយនឹងប្រព័ន្ធគតិយុត្តសំខាន់ៗ តាមច្បាប់បារាំង ជាទឧទាហរណ៍ ការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវតែកំណត់ទៅតាមករណីនីមួយៗ ដោយមិនគិតពីបញ្ហាថាតើជនជាប់ចោទត្រូវបានរកឃើញថា ពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការនៅក្នុងកិច្ចដំណើរការនីតិវិធីដទៃទៀត ឬថាតើ ជនជាប់ចោទស្ថិតក្រោមអាណាព្យាបាលទូទៅ

---

ដែរ ឬយ៉ាងណានោះទេ។ សូមមើលមាត្រា ១២២ ដល់ ១ នៃក្រមព្រហ្មទណ្ឌបារាំង។ *សូមមើល* Bernard Bouloc, *Droit pénal général*, Paris, Dalloz, 20th ed., 2007, កថាខណ្ឌ 420, *stating*: "*Il n'existe pas en droit pénal de présomption de trouble psychique ou neuro-psychique comme en droit civil où, en cas de mise en tutelle d'un incapable majeur, tous les actes passés après le jugement d'ouverture de la tutelle sont nuls de plein droit, même s'ils ont été passés dans un intervalle lucide. Que le délinquant soit en tutelle ou non, interné dans un asile d'aliénés ou en liberté, dans tous les cas, il appartient au juge répressif de décider s'il était ou non sous l'empire d'un trouble psychique ou neuro-psychique au moment où il a commis l'infraction. La détermination de la perte du libre arbitre est donc une* question de fait, *laissée à l'appréciation et à la décision souveraine des juges du fond.*"។ ទោះបីជាយ៉ាងណាក៏ដោយ មុនពេលសាលក្រមលើអង្គសេចក្តីអាចចេញបានលើបទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងជនជាប់ចោទដែលស្ថិតក្រោមអាណាព្យាបាលនោះ ជនជាប់ចោទត្រូវទទួលនូវការវាយតម្លៃផ្នែកវេជ្ជសាស្ត្រ ដើម្បីកំណត់នូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ នៅពេលដែលបទល្មើសនេះបានប្រព្រឹត្តឡើង។ *សូមមើល* មាត្រា ៧០៦ ដល់ ១១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។ បន្ថែមលើនេះ មាត្រា ៧០៦ ដល់ ១១៣ ១១៤ និង ១១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ធានានូវការតំណាងផ្នែកច្បាប់ដោយប្រសិទ្ធិភាពនៃជនជាប់ចោទដែលគ្មានសម្បទាដែលប្រឈមមុខនឹងការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ ហើយចែងថា អាណាព្យាបាល*ពិសេស*អាចត្រូវបានចាត់តាំងដោយចៅក្រមស៊ើបអង្កេត ឬ រដ្ឋអាជ្ញា ប្រសិនបើមានហេតុផលអាចជឿបានថា អាណាព្យាបាលចូលរួមក្នុងការប្រព្រឹត្តបទល្មើស។ ប្រហាក់ប្រហែលគ្នាដែល តាមច្បាប់អាឡឺម៉ង់ សេចក្តីសម្រេចដែលចេញដោយតុលាការក្នុងកិច្ចដំណើរការនីតិវិធីមួយចំនួន ជាទូទៅ ចងកាតព្វកិច្ចភាគីនៃការជំនុំជម្រះនោះ ហើយមិនបានបង្កើតជាអង្គហេតុសម្រាប់ការជំនុំជម្រះនាពេលអនាគតឡើយ។ តុលាការអាចប្រើប្រាស់សេចក្តីសម្រេចពីដំបូងជាការចង្អុលបង្ហាញសម្រាប់សេចក្តីសម្រេចរបស់ខ្លួននៅក្នុងការជំនុំជម្រះថ្មី ប៉ុន្តែទាំងនេះ មិនបានរារាំងចៅក្រមក្នុងការពិនិត្យលើកាលៈទេសៈដែលកើតមាននៅពេលចេញសេចក្តីសម្រេចថ្មីនេះ។ *សូមមើល* Bundesgerichtshof, 17 June 2008, 4 StR 77/08, NStZ 2008, 685 *and* Bundesgerichtshof, 09 March 2010, 4 StR 640/09, NStZ 2010, 529។ អ្នកអាណាព្យាបាលដែលបានចាត់តាំង សម្រាប់ជនដែលកើតវិបល្លាស្មារតី នៅតែជាអ្នកអាណាព្យាបាលទូទៅដែលស្ថិតក្រោមកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ហើយទទួលខុសត្រូវចំពោះការស្វែងរកមេធាវីការពារក្តី។ *សូមមើល*ក្នុង: Muenchener Kommentar, BGB. Sect. 1896, para. 101. នៅក្នុងប្រទេសអង់គ្លេស និងវ៉ែល សមត្ថភាពស្របច្បាប់ដែលមានលក្ខណៈអកម្មក្នុងការឆ្លើយតប ដោយមិនគិតពីសម្បទាគ្រប់គ្រាន់នោះទេ បង្ហាញច្បាស់ថា ប្រសិនបើចៅក្រមយល់ឃើញថា ជនជាប់ចោទគ្មានសម្បទាក្នុងឆ្លើយ គណៈវិនិច្ឆ័យនឹងសម្រេចថាតើ ជនជាប់ចោទនេះបានប្រព្រឹត្តអំពើសកម្ម ឬអកម្មដែលបានចោទប្រលើរូបខ្លួនដែរ ឬយ៉ាងណា។ សូមមើល ផ្នែក 4A, នីតិវិធីព្រហ្មទណ្ឌ (វិបល្លាសស្មារតី) ច្បាប់ ឆ្នាំ ១៩៦៤។ *សូមមើល* ការណែនាំផ្លូវច្បាប់ស្តីពីជនល្មើសមានវិបល្លាសស្មារតីនៃ Crown Prosecution Service និងការពិភាក្សាស្តីពីការបង្វែរ និងការពិចារណាពីផលប្រយោជន៍សាធារណៈ ក្នុងការចោទប្រកាន់ជនមានវិបល្លាសស្មារតី។ យោងតាមច្បាប់ស្តីពីសម្បទាឆ្នាំ ២០០៥, "តុលាការអាចធ្វើការបង្គាប់[…]ឬផ្តល់សេចក្តីណែនាំ និងប្រគល់អំណាចទៅប៉ូលីស ឬប្រគល់កាតព្វកិច្ច នៅពេលដែលខ្លួនយល់ថាចាំបាច់សម្រាប់គោលបំណងក្នុងការរៀបចំ និងចាត់ចែងអចលវត្ថុ និងកិច្ចការផ្សេងៗរបស់ជនវិបល្លាសស្មារតីនេះ ជាពិសេសចំពោះអនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធីជំនួសបាន"។

អនាគត ចាំបាច់ត្រូវតែធ្វើការពិចារណាជាស្វ័យប្រវត្តិ ចំណែកឯអង្គហេតុដែលមានក្នុងកិច្ចដំណើរការនីតិវិធីមុនៗទាំងនេះ ត្រូវពិចារណាដោយផ្អែកលើតម្លៃនៃភស្តុតាង។

15. អំពើណាមួយ ដែលស្តែងឱ្យឃើញជាសត្យានុម័តនូវការរំលោភបំពានទៅលើលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការ គឺមានភាពចាំបាច់ត្រូវស្វែងរកឱ្យឃើញនូវធាតុអត្តនោម័ត។ នៅក្នុងករណីដែលជនមានបញ្ហាខាងបញ្ញាស្មារតី ការការពារដោយលើកថាមិនមានការយល់ដឹងគ្រប់គ្រាន់ទំនងជាសមស្រប ប៉ុន្តែមិនត្រូវមើលទៅលើបញ្ហានេះដោយច្បោលៗនោះទេ។ ហេតុនេះ នៅពេលដែលការដាក់ទណ្ឌកម្មមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជានោះ ការអនុវត្តតម្រូវឱ្យមានការវាយតម្លៃលើបញ្ហាស្តីពីការទទួលខុសត្រូវ ក៏ដូចជា ភាពចាំបាច់ និងភាពសមស្រប ទៅតាមកាលៈទេសៈនីមួយៗ។ យោងតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង សូម្បីតែគ្មានធាតុអត្តនោម័តក្តី ប្រសិនបើការរំលោភលើវិធានការស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវបានចាត់ទុកថា ជាអំពើជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ វិធានការរដ្ឋបាលអាចត្រូវបានបង្គាប់ឡើង ដើម្បីបញ្ឈប់ការជ្រៀតជ្រែកនេះ ឬរាំងមិនឱ្យកើតឡើងសារជាថ្មី[30]។

16. អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា របបនៃការត្រួតពិនិត្យតាមផ្លូវតុលាការលើ អៀង ធីរិទ្ធ ត្រូវបានបង្កើតឡើងដោយមានការពិចារណាដល់ការលំបាក ដែលជនជាប់ចោទនឹងត្រូវប្រឈមមុខ ក្នុង

[30] *សូមមើល* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ឯកសារលេខ E176/2/1/4, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២, កថាខណ្ឌ ៤៤ ("លើកលែងបណ្តឹងអាជ្ញាដែលមានចែងក្នុងច្បាប់កម្ពុជា,ក្របខណ្ឌនៃវិធាន ៣៥ រួមបញ្ចូលនូវអំណាចក្នុងការ 'ចាត់វិធានការចាំបាច់ដើម្បីធានាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី ដែលរក្សានូវការគោរពយុត្តិធម៌'។ [...] ជាការសមហេតុផលក្នុងការបកស្រាយវិធាន ៣៥ ថាអាចអនុវត្តបានចំពោះការឆ្លើយតបកែតម្រូវជាច្រើនដែលជាលក្ខណៈរដ្ឋបាល។ [...] ការដាក់ទណ្ឌកម្មផ្នែករដ្ឋបាលទាំងនេះ ត្រូវស្រមជាមួយនឹងគោលការណ៍ជាមូលដ្ឋានស្តីពីភាពចាំបាច់ និងភាពសមស្រប") និង ៤៥ ("ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា វិធាន ៣៥ សម្រាប់គោលបំណងសំខាន់ក្នុងការធានាការជំនុំជម្រះប្រកបដោយប្រសិទ្ធភាព និងយុត្តិធម៌។ ពាក់ព័ន្ធបញ្ហានេះ កាតព្វកិច្ចរបស់តុលាការមិនត្រឹមតែដាក់ទណ្ឌកម្មលើការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងបញ្ឈប់ការជ្រៀតជ្រែកដែលកំពុងកើតមាន និងរារាំងមិនឱ្យកើតឡើង។ [...] ហេតុនេះ ជាការសមហេតុផលក្នុងការបកស្រាយថា អ.វ.ត.ក អាចយោងទៅលើវិធាន ៣៥ នៃវិធានផ្ទៃក្នុង ក្នុងការអនុវត្តមិនត្រឹមតែវិធានការដាក់ទណ្ឌកម្ម ប៉ុណ្ណោះទេ ថែមទាំងទទួលនូវការឆ្លើយតបដែលជាលក្ខណៈកែតម្រូវដែលមិនមែនជាការដាក់ទណ្ឌកម្ម ហើយមិនតម្រូវឱ្យមានការយល់ឃើញអំពីភាពជាប់បន្ទុក (ចេតនា), ដើម្បីធានាដល់សិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌")។

ការយល់ដឹង និងគោរពតាមលក្ខខណ្ឌនេះ[31]។ ពាក់ព័ន្ធបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលជួយសម្រួលដល់"វិធានការដែលតម្រូវឱ្យមានការចូលរួមតិចតួចរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ប្រសិនបើមាន ឬក្នុងករណីដែលតម្រូវឱ្យមានការផ្ដល់ជំនួយសមស្របដល់ជនជាប់ចោទ" បន្ថែមលើការ"ការពារសុវត្ថិភាព ... ដែលចាំបាច់ក្នុងការជួយសម្រួល និងធានានូវការគោរពនូវកាតព្វកិច្ច ដែលបានដាក់ចេញដោយតុលាការ"[32]។ ការពិចារណាយ៉ាងជាក់លាក់ ត្រូវបានធ្វើឡើងចំពោះការពិតដែលថា អាណាព្យាបាលរបស់ អៀង ធិរិទ្ធ (កូនស្រីរបស់ជនជាប់ចោទ, អៀង វិជីដា) ដែលត្រូវបានចាត់តាំង បង្ហាញពីឆន្ទៈរបស់ខ្លួនក្នុងការជួយ អៀង ធីរិទ្ធ ដើម្បីគោរពទៅតាមវិធានការដែលបានដាក់ដោយតុលាការ។ ជាងនេះទៅទៀត អង្គជំនុំជម្រះតុលាការកំពូលសូមរំឭកបន្ថែមទៀតថា "ករណីយកិច្ចរបស់អ្នកអាណាព្យាបាល រួមមានការជួយដល់ជនជាប់ចោទស្ថិតក្រោមអ្នកអាណាព្យាបាល ដើម្បីបំពេញកាតព្វកិច្ចតាមនីតិសាធារណៈ និងរួមទាំងកាតព្វកិច្ចដែលមានចែងក្នុងនីតិព្រហ្មទណ្ឌផងដែរ"[33]។ ជាក់ស្ដែង នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យមានវត្តមានរបស់ អៀង ធីរិទ្ធ ដោយសារហេតុផលណាមួយនោះ ឧទាហរណ៍ដូចជាការត្រួតពិនិត្យសុខភាពតាមការបង្គាប់របស់តុលាការនោះ អង្គជំនុំជម្រះសាលាដំបូងអាចចេញដីកាបង្គាប់ឱ្យនាំខ្លួន ដែលនៅពេលនោះ អ្នកអាណាព្យាបាលមានកាតព្វកិច្ចត្រូវសម្របសម្រួល។ ដីកាបែបនេះធ្វើឱ្យ អៀង ធីរិទ្ធ ត្រូវបានចាត់ទុកតាមផ្លូវច្បាប់ថា ជា"ជនជាប់ឃុំ"[34] ហើយបុគ្គលដែលជួយគាត់រត់គេច (ជាការសន្មត់) ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ[35]។ ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូងបាត់បង់ទំនុកចិត្តទៅលើអ្នកអាណាព្យាបាលបច្ចុប្បន្នរបស់ អៀង ធីរិទ្ធ ដោយហេតុផល

---

31 សេចក្ដីសម្រេចស្ដីពីការត្រួតពិនិត្យតាមផ្លូវតុលាការ កថាខណ្ឌ ៦២។

32 សេចក្ដីសម្រេចស្ដីពីការត្រួតពិនិត្យតាមផ្លូវតុលាការ កថាខណ្ឌ ៦២។

33 សេចក្ដីសម្រេចស្ដីពីការត្រួតពិនិត្យតុលាការ កថាខណ្ឌ ៦៣។

34 សូមមើលមាត្រា ៥៦០(២) នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ត្រូវចាត់ទុកថាជាជនជាប់ឃុំគឺ៖ [...] បុគ្គលដែលគេហៀបនឹងនាំទៅបង្ហាញខ្លួន ឬកំពុងតែនាំទៅបង្ហាញខ្លួនដល់អាជ្ញាធរតុលាការក្រោយពីការឃាត់ខ្លួន ឬដោយអនុវត្តដីកានាំខ្លួន ឬឱ្យចាប់ខ្លួន")។

35 *សូមមើល*មាត្រា ៥៤៤ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ("ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ទៅ៣(បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល អំពើដែលផ្ដល់ឱ្យចារី សហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតក្នុងបទឧក្រិដ្ឋនូវ៖ (១) ទីលំនៅ, (២) ទីកន្លែងលាក់ខ្លួន, (៣) មធ្យោបាយសម្រាប់ការរស់នៅ, (៤) គ្រប់មធ្យោបាយដែលអាចនាំឱ្យមានការងាយស្រួលក្នុងការគេចខ្លួន ឬក៏ឱ្យជននោះគេចផុតពីការស្រាវជ្រាវ។ ប៉ុន្តែត្រូវបានលើកលែងឱ្យរួចផុតពីទោស៖ (១) បុព្វញាតិ និងបច្ឆាញាតិ បងប្អូនប្រុសស្រីរបស់ចារី សហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ។ (២) សហព័ទ្ធរបស់ចារី សហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ")។

ណាមួយនោះ អង្គជំនុំជម្រះសាលាដំបូងអាចលើកយកបញ្ហានេះទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីជួយដល់ការផ្លាស់ប្តូរអ្នកអាណាព្យាបាល ឬតែងតាំងអ្នកអាណាព្យាបាលបន្ថែម ឬអ្នកគ្រប់គ្រងទៅលើអ្នកអាណាព្យាបាលនោះ[36]។ ទោះក្នុងកាលៈទេសៈណាក៏ដោយ ចំណុចសំខាន់ក្នុងរឿងក្តីបច្ចុប្បន្ន ពុំគប្បីផ្តោតទៅលើការដាក់ទណ្ឌកម្មដែលពុំមានលក្ខណៈជាក់ស្តែងនោះទេ ប៉ុន្តែគប្បីផ្តោតទៅលើការទាញយកផលប្រយោជន៍ពីឆន្ទៈរបស់ជនជាប់ចោទ អៀង ធីរិទ្ធ និងអ្នកអាណាព្យាបាលរបស់គាត់ ដើម្បីឱ្យចូលរួមសហការជាមួយ អ.វ.ត.ក។

17. ចំណុចចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា របបនៃការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ អាចនឹងត្រូវបានធ្វើការកែប្រែ នៅពេលដែលកាលៈទេសៈតម្រូវ។ ទាក់ទងបញ្ហានេះ ផ្នែកទី៧នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា"ការត្រួតពិនិត្យតាមផ្លូវតុលាការ"ផ្តល់ឆន្ទានុសិទ្ធិដ៏ទូលំទូលាយក្នុងការបង្កើតនូវវិធានការត្រួតពិនិត្យដែលមានលក្ខណៈសមស្របទៅតាមពេលវេលាណាមួយ[37]។ អាស្រ័យហេតុនេះ ប្រសិនបើវិធានការបច្ចុប្បន្នដោយមានការសហការជាមួយអ្នកអាណាព្យាបាល ឃើញថាពុំមានលក្ខណៈសមស្រប អង្គជំនុំជម្រះសាលាដំបូងអាចស្នើសុំធ្វើការកែប្រែលើវិធានការនេះ[38]។

---

[36] សេចក្តីសម្រេចស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការ កថាខណ្ឌ ៦៤ ដោយយោងទៅលើមាត្រា ១១០៥(៣), ១១០៨ និង ១១១០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

[37] *សូមមើលវិធាន* ៦៥ នៃវិធានផ្ទៃក្នុង,ដែលចែងអំពីដីការបង្គាប់ឱ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងចែងអំពីសមត្ថកិច្ចយ៉ាងទូលំទូលាយក្នុងការ"ដាក់លក្ខខណ្ឌដែលមានលក្ខណៈចាំបាច់ក្នុងការធានានូវវត្តមានរបស់ជនជាប់ចោទ ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធី និងការការពារដល់ជនដទៃទៀត"។

[38] ឧទាហរណ៍តាមមាត្រា ២២៣(៥) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងថា អំណាចក្នុងការបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទដែលស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងអំណាចក្នុងការត្រួតពិនិត្យយ៉ាងមានប្រសិទ្ធភាពលើកន្លែងស្នាក់នៅអាចត្រូវបានធ្វើប្រតិភូកម្មទៅ"បុគ្គលណា"ក៏បាន។

18. យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូល** សម្រេច:

**បញ្ជូន**សំណើរបស់មេធាវីការពារក្ដីទៅអង្គជំនុំជម្រះសាលាដំបូងវិញ ដោយបង្គាប់ឱ្យអនុវត្តនូវសេចក្ដីសម្រេចស្ដីពីការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយឥតបង្អង់ឡើយ,

**ទទួលយក**សំណើរបស់អង្គជំនុំជម្រះសាលាដំបូង ដែលសុំត្រង់ចំណុចបំភ្លឺទាក់ទងទៅនឹងបញ្ហាច្បាប់។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រឹម**